KPMG

# ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ

## របាយការណ៍ហិរញ្ញវត្ថុ
## និង
## របាយការណ៍របស់សវនករ
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009

របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
និងរបាយការណ៍របស់សវនករឯករាជ្យ ដែលភ្ជាប់មកជាមួយ គឺជាការប្រែសំរួលជាភាសាខ្មែរ
ពីរបាយការណ៍ជាភាសាអង់គ្លេស ។ ក្នុងករណីមានភាពមិនស្របគ្នារវាងភាសាទាំងពីរ
ឯកសារជាភាសាអង់គ្លេស ត្រូវបានយកជាគោល ។

# ព័ត៌មានអំពីក្រុមហ៊ុន

| | | |
|---|---|---|
| ក្រុមហ៊ុន | **ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ** | |
| ចុះបញ្ជីពាណិជ្ជកម្មលេខ | Co. 7897/05P | |
| ទីស្នាក់ការ | លេខ 39 $E_0$-$E_4$ ផ្លូវលេខ 374<br>សង្កាត់ទួលស្វាយព្រៃ 1 ខណ្ឌចំការមន<br>រាជធានីភ្នំពេញ<br>ព្រះរាជាណាចក្រកម្ពុជា | |
| ម្ចាស់ភាគហ៊ុន | លោក **អ៊ួង គឹមសេង** | |
| | លោក **អន ប៊ុនហាក់** | |
| | លោក **ផា ប៉ុណ្ណរិទ្ធី** | |
| | លោកស្រី **ស្រេង ស៊ីវឆេង** | |
| | លោក **ជេត ច័ន្ទប្រសើរ** | |
| | លោក **ផា ប៉ុណ្ណគីរី** | |
| | លោកស្រី **ម៊ុយ ស៊ីវត្ថា** | |
| ក្រុមប្រឹក្សាភិបាល | លោក **អ៊ួង គឹមសេង** | ជាប្រធានក្រុមប្រឹក្សាភិបាល |
| | លោក **អន ប៊ុនហាក់** | ជាអនុប្រធានក្រុមប្រឹក្សាភិបាល |
| | លោក **ផា ប៉ុណ្ណរិទ្ធី** | ជាសមាជិក |
| | លោកស្រី **ស្រេង ស៊ីវឆេង** | ជាសមាជិក |
| | លោក **ជេត ច័ន្ទប្រសើរ** | ជាសមាជិក |
| | លោក **ផា ប៉ុណ្ណគីរី** | ជាសមាជិក |
| ធនាគារវិកចំបង | ធនាគារ អេស៊ីលីដា ភីអិលស៊ី<br>ធនាគារ កាណាឌីយ៉ា<br>ធនាគារ អភិវឌ្ឍន៍ជនបទ<br>ធនាគារជាតិនៃកម្ពុជា | |
| សវនករ | ខេភីអឹមជី ខេមបូឌា ចំកាត់ | |

---

របាយការណ៍ជាភាសាខ្មែរនេះ គឺជាការប្រែសំរួលពីរបាយការណ៍ជាភាសាអង់គ្លេស

# ម៉ាក់ស៊ីម៉ា មីគ្រូហិរញ្ញវត្ថុ

## មាតិកា


| | | ទំព័រ |
|---|---|---|
| 1 | របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | 1 |
| 2 | របាយការណ៍របស់សវនករឯករាជ្យ | 7 |
| 3 | តារាងតុល្យការ | 10 |
| 4 | របាយការណ៍លទ្ធផល | 11 |
| 5 | របាយការណ៍បំរែបំរួលមូលនិធិម្ចាស់ហ៊ុន | 12 |
| 6 | របាយការណ៍ចលនាសាច់ប្រាក់ | 13 |
| 7 | កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ | 14 |


---

របាយការណ៍ជាភាសាខ្មែរនេះ គឺជាការប្រែសំរួលពីរបាយការណ៍ជាភាសាអង់គ្លេស

ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ
MAXIMA MIKROHERANHVATHOCO., LTD
ផ្ទះលេខ ៣៩ ផ្លូវលេខ ៣៧៤ សង្កាត់ទួលស្វាយព្រៃ ១ ខណ្ឌចំការមន ភ្នំពេញ កម្ពុជា
No.39, St. 374, Toul Svay Prey I, Chamcarmorn, Phnom Penh CAMBODIA
PHONE: (855) 23 214 240 / FAX: (855) 23 354 240
E-mail: maximacredit@yahoo.com / Web: http://www.maxima.com.kh

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានក្តីសោមនស្សរីករាយក្នុងការដាក់ជូនពិនិត្យនូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន **ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ** ហៅកាត់ថា ("ក្រុមហ៊ុន" ឬ "ម៉ាក់ស៊ីម៉ា") ដែលបានធ្វើសវនកម្មរួច សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009 ។

## សកម្មភាពចំបង

សកម្មភាពចំបងរបស់ ម៉ាក់ស៊ីម៉ា គឺផ្តល់សេវាមីក្រូហិរញ្ញវត្ថុ ដល់ប្រជាពលរដ្ឋកម្ពុជាដែលមានចំណូលតិច និងដែលមានសកម្មភាពសេដ្ឋកិច្ច តាមរយៈទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ និងសាខាមួយទៀតនៅខេត្តកណ្តាល នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009 មានដូចខាងក្រោម:

| | ដុល្លារអាមេរិក |
|---|---|
| ប្រាក់ចំណេញមុនដកពន្ធ | 71,167 |
| ពន្ធលើប្រាក់ចំណេញ | (18,809) |
| ប្រាក់ចំណេញសុទ្ធសំរាប់ការិយបរិច្ឆេទ | 52,358 |

## ទុនបំរុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបំរុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## ភាគលាភ

ក្នុងការិយបរិច្ឆេទនេះ ក្រុមប្រឹក្សាភិបាលបានសំរេចប្រកាស និងធ្វើការទូទាត់ភាគលាភជាសាច់ប្រាក់ចំនួន 20,112 ដុល្លារអាមេរិក (2008: មានចំនួន 13,935 ដុល្លារអាមេរិក) ដែលស្មើនឹង 50% នៃប្រាក់ចំណេញសុទ្ធ ក្នុងឆ្នាំ 2008 បន្ទាប់ពីការផ្ទេរនូវទឹកប្រាក់ចំនួន 2,114 ដុល្លារអាមេរិក (ស្មើនឹង 5% នៃប្រាក់ចំណេញសុទ្ធក្នុងឆ្នាំ 2008) ទៅទុនបំរុងនៅក្នុងមូលនិធិម្ចាស់ហ៊ុន ។

---
របាយការណ៍ជាភាសាខ្មែរនេះ គឺជាការប្រែសំរួលពីរបាយការណ៍ជាភាសាអង់គ្លេស

# ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍លទ្ធផល និងតារាងតុល្យការរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការណ៍ ដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាវិធានការណ៍ទាក់ទងទៅនឹងការលុបបំបាត់ចោលឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យ ត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលមានការជឿជាក់ថារាល់ឥណទានដែលបានដឹងថាមិនអាចទារបាន ត្រូវបានលុបបំបាត់ចោល ហើយសំវិធានធនគ្រប់គ្រាន់ត្រូវបានកំណត់ឡើងសំរាប់ឥណទានដែលជាប់សង្ស័យ ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងបណ្តាលឱ្យចំនួននៃការលុបបំបាត់ចោលឥណទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះមានលក្ខណៈមិនគ្រប់គ្រាន់រហូតដល់កំរិតជាសារវ័ន្តណាមួយនោះទេ ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍លទ្ធផល និងតារាងតុល្យការរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការណ៍ដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មចរន្តក្រៅពីបំណុលដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែលមានតម្លៃមិនអាចលក់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចលក់បានជាក់ស្តែង ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឱ្យប៉ះពាល់ដល់ការកំណត់តម្លៃ ទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវនោះទេ ។

## វិធីសាស្រ្តកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តនីវិធីសាស្រ្ត ដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងទ្រព្យអកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ ។

## បំណុលយថាភាព និងទ្រព្យអកម្មផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះ ពុំមានៈ

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលកើតមានឡើងចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមក ក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ឬ

(ខ) បំណុលយថាភាពណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន ។

# ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ

## បំណុលយថាភាព និងទ្រព្យអកម្មផ្សេងៗទៀត (បន្ត)

តាមមតិរបស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាភាព ឬទ្រព្យអកម្មផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងរយៈពេល 12 ខែ បន្ទាប់ពីថ្ងៃបញ្ចប់នៃការិយបរិច្ឆេទ នឹងមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវ័ន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់ ។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានរៀករៀកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឱ្យមានតួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ ។

## ប្រតិបត្តិការមិនប្រក្រតី

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទនេះ មិនមានការប៉ះពាល់ជាសារវ័ន្តណាមួយដល់ចំណាត់ថ្នាក់ សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយ ដែលមានលក្ខណៈជាសារវ័ន្ត និងមិនធម្មតានោះទេ ។

ក្រុមប្រឹក្សាភិបាលក៏មានយោបល់ផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទ ដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវ័ន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ ។

## ព្រឹត្តិការណ៍ចាប់តាំងពីកាលបរិច្ឆេទនៃតារាងតុល្យការ

ពុំមានព្រឹត្តិការណ៍សំខាន់ៗ កើតមានឡើងនៅក្រោយថ្ងៃនៃតារាងតុល្យការ ដែលតំរូវឱ្យមានការបង្ហាញ ឬការធ្វើនិយ័តកម្មនោះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ដែលបានបម្រើការក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះ រួមមាន:

- លោក **អ៊ឹង គឹមសេង** ជាប្រធានក្រុមប្រឹក្សាភិបាល
- លោក **អន ប៊ុនហាក់** ជាអនុប្រធានក្រុមប្រឹក្សាភិបាល
- លោក **ផា ប៉ុណ្ណរិទ្ធី** ជាសមាជិក
- លោកស្រី **ស្រេង ស៊ីវឆេង** ជាសមាជិក
- លោក **ជេត ចំន្ទប្រសើរ** ជាសមាជិក
- លោក **ផា ប៉ុណ្ណគីរី** ជាសមាជិក

## ចំណែកហ៊ុនរបស់ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល គឺជាម្ចាស់ភាគហ៊ុន និងជាអ្នកកាន់កាប់ភាគហ៊ុនរបស់ក្រុមហ៊ុន ។ ព័ត៌មានលំអិតរបស់ម្ចាស់ភាគហ៊ុន មានដូចខាងក្រោម:

| | 2009 | | 2008 | |
|---|---|---|---|---|
| ម្ចាស់ភាគហ៊ុន | ការកាន់កាប់ | ចំនួនភាគហ៊ុន | ការកាន់កាប់ | ចំនួនភាគហ៊ុន |
| លោកស្រី **ស្រេង ស៊ីវឆេង** | 29.27% | 12,000 | 24.08% | 6,500 |
| លោក **អ៊ឹង គឹមសេង** | 24.39% | 10,000 | 22.22% | 6,000 |
| លោក **អន ប៊ុនហាក់** | 24.39% | 10,000 | 25.93% | 7,000 |
| លោក **ជេត ចំន្ទប្រសើរ** | 9.75% | 4,000 | 11.48% | 3,100 |
| លោក **ផា ប៉ុណ្ណរិទ្ធី** | 7.32% | 3,000 | 8.89% | 2,400 |
| លោក **ផា ប៉ុណ្ណគីរី** | 2.44% | 1,000 | 3.70% | 1,000 |
| | 97.56% | 40,000 | 96.30% | 26,000 |

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងនិងចុងការិយបរិច្ឆេទហិរញ្ញវត្ថុ ពុំមានការរៀបចំណាមួយដែលមានក្រុមហ៊ុនជាគូភាគីមួយក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាល ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយមធ្យោបាយនៃការទិញយកភាគហ៊ុន ឬលិខិតបំណុល ឬពីក្រុមហ៊ុនដទៃទៀតទេ ។

## ម៉ាក់ស៊ីម៉ា មីគ្រូហិរញ្ញវត្ថុ

### អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល (បន្ត)

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុកន្លងទៅ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅអំពីអត្ថប្រយោជន៍ដែលបានរួមបញ្ចូលនៅក្នុងចំនួនបរិលាភសរុប ទទួលបានដោយសមាជិកក្រុមប្រឹក្សាភិបាល ដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយក្រុមហ៊ុនពាក់ព័ន្ធមួយជាមួយនឹងក្រុមហ៊ុន ដែលសមាជិកក្រុមប្រឹក្សាភិបាលជាសមាជិក ឬក៏ជាមួយក្រុមហ៊ុន ដែលសមាជិកក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើននោះទេ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ ហិរញ្ញវត្ថុ ។

### ដើមទុន

នៅក្នុងការិយបរិច្ឆេទ ក្រុមហ៊ុនបានបង្កើនដើមទុនពី 270,000 ដុល្លារអាមេរិក ដល់ 410,000 ដុល្លារអាមេរិក ហើយការ បង្កើនដើមទុននេះ ត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជានាថ្ងៃទី 30 ខែ កក្កដា ឆ្នាំ 2009 ។

### ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវ ដើម្បីចង្អុលបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009 និងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពចលនាសាច់ប្រាក់សំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវៈ

(ក) អនុម័តនូវគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តន៍ឱ្យបានជាប់លាប់ ។

(ខ) គោរពទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ឬបើមានការផ្លាស់ប្តូរពីនេះ ដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវ គឺត្រូវធ្វើកំណត់បង្ហាញ និងពន្យល់ឱ្យបានច្បាស់លាស់ និងកំណត់បរិមាណឱ្យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

(គ) រក្សាទុកនូវបញ្ជីគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធនៃការគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធិភាព ។

របាយការណ៍ជាភាសាខ្មែរនេះ គឺជាការប្រែសំរួលពីរបាយការណ៍ជាភាសាអង់គ្លេស

# ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ (បន្ត)

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម លុះត្រាតែមានករណីមិនសមរម្យក្នុងការសន្មត់ថា ក្រុមហ៊ុននឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មនាពេលអនាគតដែលគិតទុកជាមុន និង

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធិភាពលើរាល់សេចក្តីសំរេច ដែលមានសារៈសំខាន់ទាំងអស់ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការ ហើយត្រូវធ្វើឱ្យប្រាកដថា កិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តនូវរាល់តម្រូវការដូចមានរាយការណ៍ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ។

*ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាលៈ*

លោក **អ៊ុង គីមសេង**
*ប្រធានក្រុមប្រឹក្សាភិបាល*

ថ្ងៃទី: 26 APR 2010

KPMG Cambodia Ltd
No. 2, Street 208
Sangkat Beoung Prolit
Khan 7 Makara, Phnom Penh
Kingdom of Cambodia

Telephone +855 (23) 216 899
Fax +855 (23) 217 279
Internet www.kpmg.com

# របាយការណ៍របស់សវនករឯករាជ្យ
## ជូនចំពោះម្ចាស់ភាគហ៊ុនរបស់
## ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន **ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ** ហៅកាត់ថា (“ក្រុមហ៊ុន” ឬ “ម៉ាក់ស៊ីម៉ា”) ដែលរួមមាន តារាងតុល្យការនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009 និងរបាយការណ៍លទ្ធផល របាយការណ៍បំរែបំរួលមូលនិធិម្ចាស់ហ៊ុន និងរបាយការណ៍ចលនាសាច់ប្រាក់ សំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងសេចក្តីសង្ខេបលើគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងកំណត់សំគាល់ផ្សេងៗ ដែលបានបង្ហាញនៅទំព័រទី 10 ដល់ទី 54 ។ តួលេខប្រៀបធៀបដែលបានបង្ហាញ គឺផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008 ដែលបានធ្វើសវនកម្មដោយក្រុមហ៊ុនសវនកម្មផ្សេងទៀត ដែលក្នុងរបាយការណ៍របស់ខ្លួនចុះថ្ងៃទី 21 ខែ មេសា ឆ្នាំ 2009 បានបញ្ចេញមតិថា របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវភាពពិត និងត្រឹមត្រូវ ។

### ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងរបស់ក្រុមហ៊ុនមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ ការទទួលខុសត្រូវនេះរួមមានការបង្កើត ការអនុវត្តន៍ និងការរក្សានូវប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការរៀបចំ និងការបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ឱ្យជៀសផុតពីកំហុសឆ្គងជាសារវ័ន្តដោយសារការក្លែងបន្លំ ឬការភាន់ច្រឡំ ជ្រើសរើស និងអនុវត្តគោលនយោបាយគណនេយ្យសមស្រប និងការប្រើប្រាស់គណនេយ្យប៉ាន់ស្មានដែលសមស្រប ទៅតាមកាលៈទេសៈ ។

### ការទទួលខុសត្រូវរបស់សវនករ

ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺធ្វើការបញ្ចេញមតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុផ្អែកទៅលើការធ្វើសវនកម្មរបស់យើងខ្ញុំ ។ លែកលែងតែការបង្ហាញក្នុងកថាខ័ណ្ឌ ដែលបានបញ្ជាក់ពីមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់ដែលមានបញ្ហា យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិ ។ ស្តង់ដារទាំងនេះ តម្រូវឱ្យយើងខ្ញុំអនុវត្តទៅតាមតម្រូវការក្រមសីលធម៌ដែលពាក់ព័ន្ធ ដោយគ្រោងនិងធ្វើសវនកម្ម ដើម្បីទទួលបាននូវអំណះអំណាងយ៉ាងសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុពុំមានកំហុសឆ្គងជាសារវ័ន្តឡើយ ។



KPMG Cambodia Ltd., a Cambodian limited liability company and a member firm of the KPMG network of independent member firms affiliated with KPMG International a Swiss Cooperative
All rights reserved

ការធ្វើសវនកម្ម រួមមានការអនុវត្តន៍នូវបណ្តានិតិវិធីត្រួតពិនិត្យ ដើម្បីទទួលបាននូវភស្តុតាងដែលទាក់ទងទៅនឹងបរិមាណទឹកប្រាក់ និងកំណត់បង្ហាញទាំងឡាយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ ការជ្រើសរើសនីតិវិធីទាំងនេះគឺផ្អែកទៅលើការវិនិច្ឆ័យរបស់យើងខ្ញុំ ដែលរួមមានការប៉ាន់ប្រមាណទៅលើហានិភ័យ ដែលមានផលប៉ះពាល់ជាសារវ័ន្តលើរបាយការណ៍ហិរញ្ញវត្ថុបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ ។ នៅក្នុងការប៉ាន់ប្រមាណហានិភ័យទាំងនោះ យើងខ្ញុំធ្វើការពិចារណាទៅលើការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ពន្ធ័ទៅនឹងការរៀបចំ និងការបង្ហាញនូវភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីធ្វើសវនកម្មឱ្យសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណង ដើម្បីបញ្ចេញមតិយោបល់ទៅលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ ។

ការធ្វើសវនកម្ម ក៏រួមមានការវាយតម្លៃទៅលើភាពសមស្របនៃគោលការណ៍គណនេយ្យ ដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មានសំខាន់ៗ ដែលធ្វើឡើងដោយគណៈគ្រប់គ្រង ព្រមទាំងការវាយតម្លៃលើភាពគ្រប់គ្រាន់នៃការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប សំរាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិរបស់យើងខ្ញុំ ។

## មូលដ្ឋានក្នុងការបញ្ចេញមតិយោបល់ដែលមានបញ្ហា

ដូចបានបញ្ជាក់ក្នុងកំណត់សំគាល់ 9 នៃរបាយការណ៍ហិរញ្ញវត្ថុ នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008 ក្រុមហ៊ុន មិនបានកត់ត្រានូវចំណូលពីការប្រាក់បង្គរ ដោយសារប្រព័ន្ធតាមដានឥណទាននៅមានកំរិតនៅឡើយ ។ ប្រសិនបើការប្រាក់បង្គរត្រូវបានកត់ត្រា នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនាការិយបរិច្ឆេទមុន និយ័តកម្ម នឹងត្រូវធ្វើឡើង ដើម្បីបន្ថែមលើចំណូលពីការប្រាក់ ប្រាក់ចំណេញសុទ្ធ ការប្រាក់ត្រូវទទួល និងមូលនិធិម្ចាស់ហ៊ុនសំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008 ហើយជាលទ្ធផលនឹងបណ្តាលអោយថយចុះនូវចំណូលពីការប្រាក់ និងប្រាក់ចំណេញសុទ្ធ សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009 ។

## មតិយោបល់ដែលមានបញ្ហា

ជាមតិយោបល់របស់យើងខ្ញុំ លើកលែងតែផលប៉ះពាល់នៃការធ្វើនិយ័តកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីបញ្ហា ដូចបានរៀបរាប់នៅក្នុងកថាខ័ណ្ឌនៃមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់ដែលមានបញ្ហាខាងលើ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវ ភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុ របស់ក្រុមហ៊ុន **ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ** នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009 ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពចលនាសាច់ប្រាក់របស់ក្រុមហ៊ុនសំរាប់ការិយបរិច្ឆេទបញ្ចប់ ដោយស្របទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

KPMG

របាយការណ៍ហិរញ្ញវត្ថុដែលមានភ្ជាប់មកជាមួយ ត្រូវបានប្តូរទៅជាប្រាក់រៀល ដើម្បីអនុវត្តទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ យើងខ្ញុំបានធ្វើសវនកម្មទៅលើការប្តូរនូវរូបិយប័ណ្ណនេះ ហើយតាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលបានបង្ហាញជាដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយផ្អែកលើមូលដ្ឋានដែលបានបង្ហាញនៅក្នុងកំណត់សំគាល់ទី 4 នៃរបាយការណ៍ហិរញ្ញវត្ថុ ។

**តំណាងក្រុមហ៊ុន ខេភីអឹមជី ខេមបូឌា ចំកាត់**

**Craig McDonald**
*Audit Partner*

រាជធានីភ្នំពេញ ថ្ងៃទី 26 ខែ មេសា ឆ្នាំ 2010

# ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ

## តារាងតុល្យការ
## នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009

| | កំណត់សំគាល់ | 2009<br>ដុល្លារអាមេរិក | 2009<br>ពាន់រៀល | 2008<br>ដុល្លារអាមេរិក | 2008<br>ពាន់រៀល |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | 5 | 7,461 | 31,105 | 15,189 | 61,986 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់ នៅធនាគារនានា | 6 | 26,810 | 111,771 | 193,962 | 791,559 |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់ | 7 | 20,500 | 85,464 | 13,500 | 55,094 |
| ឥណទានផ្តល់ដល់អតិថិជន | 8 | 1,684,057 | 7,020,834 | 1,372,285 | 5,600,295 |
| គណនីត្រូវទទួលផ្សេងៗ | 9 | 35,206 | 146,773 | 10,285 | 41,973 |
| អចលនទ្រព្យ និងទ្រព្យសម្ភារៈ | 10 | 42,512 | 177,233 | 60,558 | 247,137 |
| **សរុបទ្រព្យសកម្ម** | | 1,816,546 | 7,573,180 | 1,665,779 | 6,798,044 |
| **ទ្រព្យអកម្ម និងមូលនិធិម្ចាស់ហ៊ុន** | | | | | |
| **ទ្រព្យអកម្ម** | | | | | |
| គណនីត្រូវទូទាត់ទៅម្ចាស់ហ៊ុន | 11 | 90,000 | 375,210 | 133,000 | 542,773 |
| ប្រាក់កម្ចី | 12 | 1,151,810 | 4,801,896 | 1,164,749 | 4,753,340 |
| ទ្រព្យអកម្មផ្សេងៗ | 13 | 53,708 | 223,908 | 26,984 | 110,122 |
| សំវិធានធនសំរាប់ពន្ធលើ ប្រាក់ចំណេញ | 14 | 15,388 | 64,153 | 7,652 | 31,228 |
| **សរុបទ្រព្យអកម្ម** | | 1,310,906 | 5,465,167 | 1,332,385 | 5,437,463 |
| **មូលនិធិម្ចាស់ហ៊ុន** | | | | | |
| ដើមទុន | 15 | 410,000 | 1,709,290 | 270,000 | 1,101,870 |
| ទុនបំរុង | | 9,236 | 38,505 | 7,122 | 29,065 |
| ប្រាក់ចំណេញរក្សាទុក | | 86,404 | 360,218 | 56,272 | 229,646 |
| **សរុបមូលនិធិម្ចាស់ហ៊ុន** | | 505,640 | 2,108,013 | 333,394 | 1,360,581 |
| **សរុបទ្រព្យអកម្ម និងមូលនិធិម្ចាស់ហ៊ុន** | | 1,816,546 | 7,573,180 | 1,665,779 | 6,798,044 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាបតិដ្ឋានបទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

របាយការណ៍ជាភាសាខ្មែរនេះ គឺជាការប្រែសំរួលពីរបាយការណ៍ជាភាសាអង់គ្លេស

# ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ

## របាយការណ៍លទ្ធផល
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009

| | | 2009 | | 2008 | |
|---|---|---|---|---|---|
| | កំណត់សំគាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលពីការប្រាក់ | 16 | 444,918 | 1,854,863 | 323,841 | 1,321,595 |
| ចំណាយលើការប្រាក់ | 17 | (52,413) | (218,510) | (44,465) | (181,462) |
| **ចំណូលសុទ្ធពីការប្រាក់** | | 392,505 | 1,636,353 | 279,376 | 1,140,133 |
| ចំណូលប្រតិបត្តិការផ្សេងៗ | 18 | 6,210 | 25,889 | 4,315 | 17,609 |
| **ចំណូលប្រតិបត្តិការ** | | 398,715 | 1,662,242 | 283,691 | 1,157,743 |
| ចំណាយរដ្ឋបាលទូទៅ | 19 | (294,588) | (1,228,137) | (230,066) | (938,899) |
| សំវិធានធនសំរាប់ឥណទានអាក្រក់ និងជាប់សង្ស័យ | 8 | (32,960) | (137,410) | (749) | (3,057) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | 71,167 | 296,695 | 52,876 | 215,787 |
| ពន្ធលើប្រាក់ចំណេញ | 14 | (18,809) | (78,415) | (10,584) | (43,193) |
| **ប្រាក់ចំណេញសុទ្ធសំរាប់ការិយបរិច្ឆេទ** | | 52,358 | 218,280 | 42,292 | 172,594 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាបតិដ្ឋានបទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ

## របាយការណ៍បំរែបំរួលមូលនិធិម្ចាស់ហ៊ុន
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009

| | ដើមទុន<br>ដុល្លារអាមេរិក | ទុនបំរុង<br>ដុល្លារអាមេរិក | ប្រាក់ចំណេញ<br>រក្សាទុក<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|
| សមតុល្យនាថ្ងៃទី 1 ខែ មករា ឆ្នាំ 2008 | 270,000 | 5,653 | 29,384 | 305,037 |
| ភាគលាភដែលបានបង់ | - | - | (13,935) | (13,935) |
| ការផ្ទេរចូលទុនបំរុងលក្ខន្តិកៈ | - | 1,469 | (1,469) | - |
| ប្រាក់ចំណេញសុទ្ធសំរាប់ការិយបរិច្ឆេទ | - | - | 42,292 | 42,292 |
| សមតុល្យនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2008 | 270,000 | 7,122 | 56,272 | 333,394 |
| ភាគលាភដែលបានបង់ | - | - | (20,112) | (20,112) |
| ការបង្កើនដើមទុន | 140,000 | - | - | 140,000 |
| ការផ្ទេរចូលទុនបំរុងលក្ខន្តិកៈ | - | 2,114 | (2,114) | - |
| ប្រាក់ចំណេញសុទ្ធសំរាប់ការិយបរិច្ឆេទ | - | - | 52,358 | 52,358 |
| សមតុល្យនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009 | 410,000 | 9,236 | 86,404 | 505,640 |
| (ស្មើនឹងពាន់រៀល) | 1,709,290 | 38,505 | 360,218 | 2,108,013 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាបតិដ្ឋានបទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ

## របាយការណ៍ចលនាសាច់ប្រាក់
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009

| | | 2009 | | 2008 | |
|---|---|---|---|---|---|
| | កំណត់សំគាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ចលនាសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពប្រតិបត្តិការ | 20 | (277,115) | (1,155,292) | (453,884) | (1,852,300) |
| **ចលនាសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញអចលនទ្រព្យ និងទ្រព្យសម្ភារៈ | | (4,714) | (19,653) | (57,474) | (234,551) |
| សាច់ប្រាក់ទទួលបានពីការលក់ អចលនទ្រព្យ និងទ្រព្យសម្ភារៈ | | - | - | 2,170 | 8,856 |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពវិនិយោគ | | (4,714) | (19,653) | (55,304) | (225,695) |
| **ចលនាសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ភាគលាភដែលបានបង់ | | (20,112) | (83,847) | (13,935) | (56,869) |
| ការបង្កើនដើមទុន | | 140,000 | 583,660 | - | - |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | | 565,198 | 2,356,310 | 1,429,053 | 5,831,965 |
| ការទូទាត់សងប្រាក់កម្ចី | | (578,137) | (2,410,253) | (761,223) | (3,106,551) |
| សាច់ប្រាក់សុទ្ធទទួលបានពី សកម្មភាពហិរញ្ញប្បទាន | | 106,949 | 445,870 | 653,895 | 2,668,545 |
| **ការ(ថយចុះ)/កើនឡើងនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | (174,880) | (729,075) | 144,707 | 590,550 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ** | | 209,151 | 848,735 | 64,444 | 262,995 |
| លំអៀងពីការប្តូររូបិយប័ណ្ណ | | - | 23,216 | - | - |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ** | 21 | 34,271 | 142,876 | 209,151 | 853,545 |

កំណត់សំគាល់ដូចមានភ្ជាប់ជាមួយ គឺជាបតិដ្ឋានបទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009

## 1. សាវតា និងសកម្មភាពចំបង

ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ ហៅកាត់ថា (“ក្រុមហ៊ុន” ឬ “ម៉ាក់ស៊ីម៉ា”) ពីមុនមានឈ្មោះថា អង្គការម៉ាក់ស៊ីម៉ា ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ ជាគ្រឹះស្ថានហិរញ្ញវត្ថុដែលបានបង្កើតឡើងនៅ ព្រះរាជាណាចក្រកម្ពុជា និងបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី 27 ខែ កក្កដា ឆ្នាំ 2005 ក្រោមបញ្ជីពាណិជ្ជកម្មលេខ Co. 7897/05P និងបានទទួលអាជ្ញាប័ណ្ណប្រកបអាជីវកម្មជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី 10 ខែ សីហា ឆ្នាំ 2005 ។ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណជា អចិន្ត្រៃយ៍ ពីធនាគារជាតិនៃកម្ពុជា ដើម្បីប្រកបអាជីវកម្មជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្នុងខែ មិថុនា ឆ្នាំ 2008 ។

ទស្សនៈវិស័យរបស់ក្រុមហ៊ុន គឺប្រមូលផ្តុំប្រជាពលរដ្ឋ និងអាជីវកម្មគ្រប់ប្រភេទ ដោយមានគោលបំណងចំបងសំដៅកាត់បន្ថយភាពក្រីក្រ តាមរយៈការផ្តល់ដល់ប្រជាពលរដ្ឋរស់នៅតំបន់ជនបទ នូវឱកាសខាងសេដ្ឋកិច្ច និងសង្គម។ បេសកកម្មរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មហិរញ្ញវត្ថុ ជូនដល់ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាបជាលក្ខណៈឯកត្តជន ជាក្រុម និងអាជីវកម្មខ្នាតតូច-មធ្យម ជាពិសេសគ្រួសារក្រីក្រដែលមានស្ត្រីជាមេគ្រួសារ និង ធ្វើសកម្មភាពប្រមូលប្រាក់សន្សំផងដែរ។

ក្រុមហ៊ុនធ្វើប្រតិបត្តិការផ្តល់សេវាកម្មហិរញ្ញវត្ថុ នៅទីស្នាក់ការកណ្តាលនៃរាជធានីភ្នំពេញ និងមានសាខាមួយនៅខេត្តកណ្តាល ។

ក្រុមហ៊ុនមាន បុគ្គលិកចំនួន 50 នាក់ នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009 (2008: មានបុគ្គលិកចំនួន 48 នាក់) ។

## 2. មូលដ្ឋាននៃការរៀបចំ

### (ក) របាយការណ៍នៃការអនុវត្តតាម

របាយការណ៏ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងស្របតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៏ណែនាំរបស់ធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៏ហិរញ្ញវត្ថុ ។

របាយការណ៏ហិរញ្ញវត្ថុ ត្រូវបានអនុម័ត និងអនុញ្ញាតចេញដោយក្រុមប្រឹក្សាភិបាល នាថ្ងៃទី 26 ខែ មេសា ឆ្នាំ 2010 ។

### (ខ) មូលដ្ឋាននៃការវាស់វែង

របាយការណ៏ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងតាមមូលដ្ឋានតម្លៃដើម ។

## 2. មូលដ្ឋាននៃការរៀបចំ (បន្ត)

### (គ) រូបិយប័ណ្ណសំរាប់ការវាស់វែង និងការកំណត់បង្ហាញ

ក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនជាប្រាក់ដុល្លារអាមេរិក ។ គណៈគ្រប់គ្រង បានកំណត់ ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណ សំរាប់ការវាស់វែង និងការកំណត់បង្ហាញ ដោយសារតែវាឆ្លុះ បញ្ចាំងពីសារធាតុសេដ្ឋកិច្ច នៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន ។

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗទៀតក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ ។ ទ្រព្យសកម្ម និងទ្រព្យអកម្មដែលជារូបិយប័ណ្ណផ្សេងទៀត ក្រៅពីប្រាក់ដុល្លារអាមេរិក ក៏ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើប្រាស់អត្រានាថ្ងៃតារាងតុល្យការ ។ ភាពលំអៀង ពីការប្តូររូបិយប័ណ្ណដែលកើតមកពីការប្តូរនោះ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។

### (ឃ) ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ តម្រូវឱ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មតដែលប៉ះពាល់ដល់ការអនុវត្តនីនូវគោលនយោបាយគណនេយ្យ និងចំនួននៃទ្រព្យសកម្ម ទ្រព្យអកម្ម ចំណូល និងចំណាយដែលបានរាយការណ៍ ។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនោះ ។

ការប៉ាន់ស្មាន និងការសន្មត ត្រូវបានពិនិត្យជាប្រចាំ ។ ការកែប្រែទៅលើគណនេយ្យប៉ាន់ស្មាន ត្រូវបានទទួល ស្គាល់ និងកត់ត្រា នៅក្នុងការិយបរិច្ឆេទដែលការប៉ាន់ស្មាននោះត្រូវបានត្រួតពិនិត្យឡើងវិញ និងនៅក្នុងកំឡុងការិយបរិច្ឆេទ ដែលផលប៉ះពាល់នោះ នឹងកើតមានឡើងនាពេលអនាគត។

ការប៉ាន់ស្មាន និងការវិនិច្ឆ័យគណនេយ្យចំបង ត្រូវបានអនុវត្តនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួមមាន ការប៉ាន់ស្មាននូវចំនួនដែលអាចប្រមូលបានមកវិញពីឥណទានផ្តល់ដល់អតិថិជន ដែលបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យ ដោយឡែកក្នុងកំណត់សំគាល់ 3 (ង) ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗខាងក្រោមនេះ ត្រូវបានអនុវត្តដោយក្រុមហ៊ុនក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ។ គោលនយោបាយទាំងអស់នេះក៏ត្រូវយកមកអនុវត្តផងដែរក្នុងការិយបរិច្ឆេទមុនៗ លើកលែងតែចំនុចណាដែលបានបញ្ជាក់ ។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (បន្ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (បន្ត)

#### (ក) ឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្ម និងទ្រព្យអកម្មហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមមានសាច់ប្រាក់ និងសាច់ប្រាក់សមមូលការផ្តល់ឥណទាន និងទ្រព្យសកម្មផ្សេងៗ ប្រាក់កម្ចី និងទ្រព្យអកម្មផ្សេងៗ ។ គោលនយោបាយគណនេយ្យលើការទទួលស្គាល់ និងការវាយតម្លៃនូវសមាសធាតុទាំងនេះ ត្រូវបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យដោយឡែកពីគ្នា ។

#### (ខ) ព័ត៌មាននិយោគកម្ម

ក្រុមហ៊ុនធ្វើប្រតិបត្តិការក្នុងវង្វង់អាជីវកម្មរបស់ខ្លួន គឺសេវាកម្មមីក្រូហិរញ្ញវត្ថុ និងស្ថិតនៅក្នុងដែនភូមិសាស្រ្តតែមួយគឺ ព្រះរាជាណាចក្រកម្ពុជា ។

#### (គ) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ និងសមតុល្យធនាគារ ប្រាក់បញ្ញើគ្មានកាលកំណត់ និងការវិនិយោគរយៈពេលខ្លី ដែលអាចប្តូរជាសាច់ប្រាក់បានក្នុងរយៈពេល 3 ខែ ឬតិចជាងនាពេលទិញ និងដែលអាចប្តូរជាសាច់ប្រាក់ ដែលមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ ។

#### (ឃ) ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជន ដែលបានបង្ហាញនៅក្នុងតារាងតុល្យការ ត្រូវបានកត់ត្រាតាមថ្លៃដើមដែលនៅសល់ដកចំនួនដែលបានលុបចោល សំវិធានធនជាក់លាក់ និងសំវិធានធនទូទៅ ។ ឥណទានរយៈពេលខ្លីគឺជាឥណទានដែលត្រូវបង់មកវិញក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីថ្ងៃ ដែលឥណទានបានផ្តល់ឱ្យ ។ ឥណទាន រយៈពេលវែងគឺជាឥណទានដែលកាលបរិច្ឆេទ ក្នុងការទទួលការទូទាត់ មានរយៈពេលលើសពីមួយឆ្នាំ គិតចាប់ពីថ្ងៃដែលឥណទានបានផ្តល់ឱ្យ ។

ភាពគ្រប់គ្រាន់នៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ ត្រូវបានវាយតម្លៃដោយគណៈគ្រប់គ្រងជារៀងរាល់ខែ ។ លក្ខខណ្ឌទាំងឡាយត្រូវបានពិចារណាក្នុងការវាយតម្លៃទៅលើភាពគ្រប់គ្រាន់នៃសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យមានដូចជា ទំហំនៃឥណទាន បទពិសោធន៍នៃការខាតបង់កន្លងទៅ លក្ខខណ្ឌសេដ្ឋកិច្ចបច្ចុប្បន្ន និងផលប៉ះពាល់ផ្សេងៗដល់អតិថិជន ស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន និងស្ថានភាពជាក់ស្តែងនៃឥណទានធៀបនឹងលក្ខខណ្ឌ ដែលបានចែងនៅក្នុងកិច្ចសន្យា ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (បន្ត)

### (ង) សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ

ដើម្បីអនុលោមទៅតាមការណែនាំរបស់ធនាគារជាតិនៃកម្ពុជា សំវិធានធនជាក់លាក់លើឥណទានអាក្រក់ និងជាប់សង្ស័យ ត្រូវបានធ្វើតែទៅលើឥណទានដែលបានចាត់ទុកថាមិនដំណើរការ ដែលត្រូវធ្វើឡើងដូចខាងក្រោម:

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃដែលហួសកាលកំណត់សង | អត្រាសំវិធានធន |
|---|---|---|
| **ឥណទានរយៈពេលខ្លី (តិចជាងមួយឆ្នាំ):** | | |
| ឥណទានក្រោមស្តង់ដារ | ពី 31 ទៅ 60 ថ្ងៃ | 10% |
| ឥណទានជាប់សង្ស័យ | ពី 61 ទៅ 90 ថ្ងៃ | 30% |
| ឥណទានបាត់បង់ | លើសពី 90 ថ្ងៃ | 100% |
| **ឥណទានរយៈពេលវែង (លើសពីមួយឆ្នាំ):** | | |
| ឥណទានក្រោមស្តង់ដារ | ពី 31 ទៅ 180 ថ្ងៃ | 10% |
| ឥណទានជាប់សង្ស័យ | ពី 181 ទៅ 360 ថ្ងៃ | 30% |
| ឥណទានបាត់បង់ | លើសពី 360 ថ្ងៃ | 100% |

សំវិធានធនជាក់លាក់ ត្រូវបានគណនាជាភាគរយលើឥណទានដែលនៅសល់ នៅពេលដែលឥណទាននោះត្រូវបានចាត់ថ្នាក់ ដោយមិនរាប់បញ្ចូលនូវការប្រាក់បង្គរទុកឡើយ ហើយត្រូវបានចាត់ជាចំណាយ ។

ក្នុងការកំណត់នូវសំវិធានធនខាងលើ តម្លៃវត្ថុដាក់បញ្ចាំមិនត្រូវបានយកមកគិតបញ្ចូលឡើយ លើកលែងតែក្នុងករណី ដែលឥណទានត្រូវបានចាត់ថ្នាក់ជាឥណទានបាត់បង់ តម្លៃវត្ថុដាក់បញ្ចាំអាចត្រូវបានយកមកប្រើប្រាស់តាមតំលៃទីផ្សារ ដែលបានអនុម័តដោយធនាគារជាតិនៃកម្ពុជា ។

បន្ថែមលើសំវិធានធនជាក់លាក់ខាងលើ សំវិធានធនទូទៅសំរាប់ឥណទានអាក្រក់ និងជាប់សង្ស័យ ត្រូវបានធ្វើឡើងសំរាប់ចំនួនដែលនៅសល់ទាំងអស់នៃឥណទានក្រោមស្តង់ដារ ដោយគិតតាមអត្រា 90% នៃឥណទានក្រោមស្តង់ដារ និងឥណទានជាប់សង្ស័យតាមអត្រា 70% នៃឥណទានជាប់សង្ស័យ ។

ឥណទានដែលមិនអាចទារបាន ឬចំណែកនៃឥណទានដែលបានចាត់ថ្នាក់ជាឥណទានអាក្រក់ត្រូវបានលុបបំបាត់ចោល នៅពេលដែលអ្នកគ្រប់គ្រងវិនិច្ឆ័យឃើញថា ពុំមានសង្ឃឹមនឹងទារបាននូវឥណទានទាំងនោះ មកវិញទេ បន្ទាប់ពីបានពិចារណាទៅលើការវាយតម្លៃវត្ថុបញ្ចាំដែលនៅសល់បើសិនមាន ហើយទទួលបានអនុញ្ញាតិពីក្រុមប្រឹក្សាភិបាល ។ ឥណទានដែលត្រូវបានលុបបំបាត់ចោលត្រូវបានយកចេញពីឥណទានដែលនៅសល់ និងដកពីសំវិធានធនសំរាប់ឥណទានអាក្រក់ និងជាប់សង្ស័យ ។ ការប្រមូលបានមកវិញនូវឥណទាន ដែលបានលុបបំបាត់ចោលពីពេលមុន ត្រូវបានកត់ជាចំណូលប្រតិបត្តិការផ្សេងៗ នៅក្នុងរបាយការណ៍លទ្ធផល ។

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (បន្ត)

**(ច) ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា**

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា ត្រូវបានកត់ត្រាតាមតម្លៃដើម ។

**(ឆ) គណនីត្រូវទទួលផ្សេងៗ**

គណនីត្រូវទទួលផ្សេងៗ ត្រូវបានកំណត់តាមតម្លៃដែលបានប៉ាន់ស្មានថាអាចប្រមូលមកវិញបាន ។ ការប៉ាន់ស្មានត្រូវបានធ្វើឡើងសំរាប់គណនីត្រូវទទួលជាប់សង្ស័យ ដោយផ្អែកទៅលើការត្រួតពិនិត្យ នៃចំនួនដែលនៅសល់នាចុងការិយបរិច្ឆេទ ។

**(ជ) អចលនទ្រព្យ និងទ្រព្យសម្ភារៈ**

(i) អចលនទ្រព្យ និងទ្រព្យសម្ភារៈ ត្រូវបានកត់ត្រាតាមតម្លៃដើមដកនូវរំលស់បង្គរ និងការខាតបង់នៃឱនភាពតម្លៃបង្គរ ប្រសិនបើមាន ។ នៅពេលដែលធាតុនៃទ្រព្យសម្បត្តិរួមបញ្ចូលនូវសមាសធាតុសំខាន់ៗ ដែលមានអាយុកាលកំណត់ប្រើប្រាស់ខុសៗគ្នា អចលនទ្រព្យទាំងនោះត្រូវបានចាត់ទុកជាធាតុផ្សេងគ្នា នៃអចលនៈទ្រព្យ និងទ្រព្យសម្ភារៈ ។

(ii) រំលស់លើអចលនទ្រព្យ និងទ្រព្យសំភារៈ ត្រូវបានបញ្ចូលនៅក្នុងរបាយការណ៍លទ្ធផល ដោយផ្អែកលើមូលដ្ឋានរំលស់ថេរ ដោយគិតទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់អចលនទ្រព្យនិមួយៗ ដែលមានអត្រាដូចខាងក្រោមៈ

| | |
|---|---|
| ការជួសជុលកែលំអរ | 50% |
| សម្ភារៈការិយាល័យ និងគ្រឿងសង្ហារឹម | 20% - 50% |
| កំព្យូទ័រ និងឧបករណ៍ព័ត៌មានវិទ្យា | 50% |
| យានយន្ត | 25% |

(iii) ការចំណាយបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃអចលនទ្រព្យ និងទ្រព្យសម្ភារៈ ដែលបានទទួលស្គាល់រួចមកហើយត្រូវបាន រួមបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យសកម្ម នៅពេលដែលទ្រព្យសកម្មនេះមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ច នាពេលអនាគតដល់ក្រុមហ៊ុនលើសពីស្តង់ដារដើម ។ រាល់ការចំណាយបន្ទាប់ផ្សេងទៀត ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង ។

(iv) ចំណេញ ឬខាតពីការបោះចោល ឬការលក់ចេញនៃអចលនទ្រព្យ និងទ្រព្យសម្ភារៈណាមួយ ត្រូវបានកំណត់ដោយភាពខុសគ្នា រវាងប្រាក់ចំណូលសុទ្ធពីការលក់ និងតម្លៃយោងនៃទ្រព្យសម្បត្តិនោះ ហើយត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល នៅថ្ងៃបោះចោល ឬលក់ចេញ ។

(v) អចលនទ្រព្យ និងទ្រព្យសំភារៈដែលបានដករំលស់អស់ហើយ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ថ្ងៃដែលអចលនទ្រព្យទាំងនោះត្រូវបានលក់ចេញ ឬលុបបំបាត់ចោល ។

# ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (បន្ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (បន្ត)

**(ជ) អចលនទ្រព្យ និងទ្រព្យសម្ភារៈ (បន្ត)**

(vi) តម្លៃយោងនៃអចលនទ្រព្យ និងទ្រព្យសម្ភារៈ ត្រូវបានត្រួតពិនិត្យឡើងវិញចំពោះឱនភាពនៃតម្លៃ នៅពេលដែលមានការគួសបញ្ជាក់ណាមួយឱ្យដឹងថា អចលនទ្រព្យនោះចាំបាច់ត្រូវបន្ថយតម្លៃ ។ ឱនភាពនៃតម្លៃត្រូវបានវាស់វែងដោយ ប្រៀបធៀបតម្លៃយោងរបស់ទ្រព្យសកម្ម ជាមួយតម្លៃដែលអាចប្រមូលបានវិញ ។ ការខាតបង់លើការថយចុះនៃតម្លៃត្រូវបានចាត់ចូលជាបន្ទុកចំណាយក្នុងរបាយការណ៍លទ្ធផល ។

**(ឈ) ឱនភាពនៃតម្លៃ**

(i) ទ្រព្យសកម្មហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាយតម្លៃ នៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ ដើម្បីកំណត់ថា តើមានភស្តុតាងណាមួយដែលបង្ហាញថា ឱនភាពអាចកើតមានឡើង ។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវចាត់ទុកថាមានឱនភាព ក្នុងករណីដែលអាចបង្ហាញថា មានហេតុការណ៍មួយឬច្រើនជះឥទ្ធិពលអវិជ្ជមាន ទៅលើចលនាសាច់ប្រាក់ នាពេលអនាគតនៃទ្រព្យសកម្មនោះ ។ ករណីនេះមិនត្រូវបានប្រើប្រាស់សំរាប់ឥណទានផ្តល់ដល់អតិថិជន ដែលត្រូវបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យ ដោយឡែកនៅក្នុងកំណត់សំគាល់ 3 (ង) ។

រាល់ទ្រព្យសកម្មហិរញ្ញវត្ថុសំខាន់ៗ ត្រូវបានត្រួតពិនិត្យចំពោះឱនភាពនៃតម្លៃ តាមមូលដ្ឋានទ្រព្យសកម្មនិមួយៗ ។ ទ្រព្យសកម្មហិរញ្ញវត្ថុដែលនៅសល់ ត្រូវបានវាយតម្លៃជារួមសំរាប់ទ្រព្យសកម្មដែលមានហានិភ័យឥណទានស្រដៀងគ្នា ។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវដកចេញប្រសិនបើការដកចេញអាចពាក់ព័ន្ធជាមួយនឹងព្រឹត្តការណ៍ ដែលកើតឡើងក្រោយពីការទទួលស្គាល់ការខាតបង់លើឱនភាព ។

(ii) ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្ម មិនមែនហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានត្រួតពិនិត្យនៅរាល់កាលបរិច្ឆេទរាយការណ៍ ដើម្បីកំណត់ថាតើមានកត្តាដែលនាំឱ្យមានឱនភាពឬទេ ។ ក្នុងករណីដែលមានកត្តាទាំងនោះកើតឡើង ការប៉ាន់ស្មានតម្លៃ ដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្មត្រូវបានធ្វើឡើង ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (បន្ត)

### (ញ) ឱនភាពនៃតម្លៃ (បន្ត)

(ii) ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (បន្ត)

តម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃទីផ្សារដកចំណាយលក់ចេញ ។ ដើម្បីកំណត់តម្លៃប្រើប្រាស់ ចលនាសាច់ប្រាក់ដែលរំពឹងទុកនាពេលអនាគតត្រូវបានបញ្ចុះទៅជាតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាការប្រាក់មុនដកពន្ធ ដើម្បីឆ្លុះបញ្ចាំពីការប៉ាន់ស្មានទីផ្សារបច្ចុប្បន្ន តាមតម្លៃពេលវេលានៃរូបិយវត្ថុ និងហានិភ័យជាក់លាក់របស់ទ្រព្យសកម្ម ។ ដើម្បីត្រួតពិនិត្យឱនភាពនៃតម្លៃទ្រព្យសកម្ម ត្រូវបានដាក់បញ្ចូលគ្នាទៅក្រុមតូចៗ ដែលអាចបង្កើតជាលំហូរចូលនូវសាច់ប្រាក់ពីការបន្តប្រើប្រាស់នូវទ្រព្យសកម្មនោះ ដោយមិនពឹងផ្អែកខ្លាំងលើលំហូរចូលនៃសាច់ប្រាក់របស់ទ្រព្យសកម្មដទៃទៀត ឬក្រុមទ្រព្យសកម្មដទៃទៀត (“ឯកតាបង្កើតសាច់ប្រាក់”) ។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់មានចំនួនលើសពីតម្លៃដែលអាចប្រមូលមកវិញបាន ។ ការខាតបង់ពីឱនភាពនៃតម្លៃត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល ។

### (ដ) ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានកត់ត្រាតាមតម្លៃដើម ។

### (ឋ) សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅក្នុងតារាងតុល្យការនៅពេលដែលក្រុមហ៊ុនជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ ឬកិច្ចសន្យា ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីពេលមុន និងអាចមានលទ្ធភាព ដែលតម្រូវឱ្យមានលំហូរចេញនូវអត្ថប្រយោជន៏សេដ្ឋកិច្ច ក្នុងការបំពេញនូវកាតព្វកិច្ចនោះ ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈជាសារវ័ន្ត សំវិធានធន ត្រូវបានកំណត់ដោយការបញ្ចុះតម្លៃចលនាសាច់ប្រាក់ដែលរំពឹងទុកនាពេលអនាគតតាមអត្រាមុនបង់ពន្ធ ដើម្បីឆ្លុះបញ្ចាំងពីការប៉ាន់ស្មានទីផ្សារបច្ចុប្បន្ន តាមតម្លៃពេលវេលានៃរូបិយវត្ថុ និងដោយសមស្របទៅនឹងហានិភ័យជាក់លាក់នៃទ្រព្យអកម្ម ។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (បន្ត)

### (ឱ) ប្រាក់សោធននិវត្តន៍

ប្រាក់សោធននិវត្តន៍ ត្រូវបានផ្តល់ដោយក្រុមហ៊ុន ដល់បុគ្គលិកចំនួន 10 ដុល្លារអាមេរិក ក្នុងមួយខែ សំរាប់បុគ្គលិកម្នាក់ៗ ។

ប្រាក់សោធននិវត្តន៍ ពេញលេញនឹងផ្តល់ឱ្យនិយោជិតនៅពេលដល់អាយុកាលចូលនិវត្តន៍ ឬប្រសិនបើ និយោជិតលាលែងពីការងារមុនអាយុកាលចូលនិវត្តន៍ ដោយទទួលបានចំណែកនៃប្រាក់សោធននិវត្តន៍ តាមលក្ខខណ្ឌដូចខាងក្រោម:

| ចំនួននៃឆ្នាំធ្វើការ | ភាគរយនៃប្រាក់សោធននិវត្តន៍សរុប ដែលបានផ្តល់ដល់និយោជិត |
|---|---|
| តិចជាង 3 ឆ្នាំ | - |
| លើសពី 3 ឆ្នាំ | 100% |

មិនមានការរក្សាទុកមូលនិធិដោយឡែកនោះទេ មានន័យថា ពុំមានមូលនិធិដោយឡែករក្សាក្នុងគណនីធនាគារ ដែលមានការប្រាក់ ឬទ្រព្យសកម្មផ្សេងទៀតសំរាប់ប្រាក់សោធននិវត្តន៍នេះឡើយ ។

### (ឍ) ទុនបំរុង

ដោយអនុលោមទៅតាមលក្ខន្តិកៈក្រុមហ៊ុន ត្រូវបង្វែរប្រាក់ចំណេញសុទ្ធសំរាប់ការិយបរិច្ឆេទមុន ចំនួន 5% ចូលក្នុងទុនបំរុង ។ ការបង្វែរនេះ នឹងត្រូវបញ្ឈប់នៅពេលដែលទុនបំរុងមានចំនួនស្មើនឹង 10% នៃដើមទុនដែលបានចុះបញ្ជីរបស់ក្រុមហ៊ុន ។

### (ណ) ការទទួលស្គាល់ការប្រាក់ចំណូល និងចំណាយ

ចំណូលការប្រាក់លើឥណទានត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្គរ ដោយផ្អែកទៅលើចំនួនប្រាក់ដើមនៃឥណទានដែលនៅសល់ ។ នៅពេលដែលឥណទានមួយ ក្លាយជាឥណទានមិនដំណើរការ ការកត់ត្រាការប្រាក់ ជាចំណូលត្រូវបានព្យួរទុករហូតដល់ត្រូវបានទទួលបានសាច់ប្រាក់ជាក់ស្តែង ។ ចំណូលពីការប្រាក់ត្រូវបានធ្វើការគណនាប្រចាំខែ ដោយផ្អែកលើប្រាក់ដើមដែលនៅសល់ពីខែមុន ។

ចំណាយផ្សេងៗ ត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានបង្គរ ។

## ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (បន្ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009

### 3. គោលនយោបាយគណនេយ្យសំខាន់ៗ (បន្ត)

#### (ត) ភតិសន្យា

ថ្លៃឈ្នួលក្នុងបែបផែនជាភតិសន្យាប្រតិបត្តិការ ត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលតាមវិធីសាស្ត្ររំលស់ថេរទៅតាមថេរវេលានៃការជួល ។

#### (ថ) ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញលើការចំណេញ ឬខាតប្រចាំឆ្នាំ រួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ ។ ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល លើកលែងតែក្នុងករណីដែលវាទាក់ទងទៅនឹងសមាសធាតុ ដែលត្រូវទទួលស្គាល់ជាផ្នែកមួយនៃមូលនិធិម្ចាស់ហ៊ុន ។ ក្នុងករណីនេះវាក៏ត្រូវបានកំណត់បង្ហាញជាផ្នែកមួយនៃមូលនិធិម្ចាស់ហ៊ុនផងដែរ ។

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងទុកថា ត្រូវបង់ទៅលើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំ ដោយប្រើអត្រាពន្ធ ដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅថ្ងៃតារាងតុល្យការជាមួយនិងនិយ័តកម្មណាមួយទៅលើពន្ធ ត្រូវបង់ពីឆ្នាំមុនៗ ។

ពន្ធពន្យារ ត្រូវបានកំណត់តាមវិធីសាស្ត្រតារាងតុល្យការ លើភាពលំអៀងជាបណ្តោះអាសន្ន រវាងតម្លៃយោងនៃទ្រព្យសកម្ម និងទ្រព្យអកម្ម ក្នុងគោលបំណងនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃដែលប្រើក្នុងគោលបំណងនៃការគិតពន្ធ ។ តម្លៃនៃប្រាក់ពន្ធពន្យារដែលបានកំណត់នោះ គឺផ្អែកលើលក្ខណៈនៃការជឿជាក់នឹងទទួលបាន ឬការទូទាត់ដែលនឹងកើតឡើង រវាងតម្លៃយោងនៃទ្រព្យសកម្ម និងទ្រព្យអកម្មដោយប្រើអត្រាពន្ធកំណត់នៅថ្ងៃតារាងតុល្យការ ។

ពន្ធពន្យារជាទ្រព្យសកម្ម និងអកម្ម ត្រូវបានកាត់កងគ្នា នៅពេលដែលមានសិទ្ធិស្របច្បាប់ដើម្បីកាត់កងពន្ធពន្យារជាទ្រព្យសកម្ម និងអកម្ម និងនៅពេលដែលពន្ធពន្យារទាក់ទងនឹងអាជ្ញាធរសារពើពន្ធដូចគ្នា។

ពន្ធពន្យារ ជាទ្រព្យសកម្មត្រូវបានទទួលស្គាល់តែក្នុងករណីអាចនឹងកើតមានឡើងទៅលើប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ដែលអាចប្រើប្រាស់ជាមួយនឹងទ្រព្យសកម្ម ។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានកាត់បន្ថយក្នុងករណីដែលវាមិនអាចកើតឡើង នូវអត្ថប្រយោជន៍នៃពន្ធដែលពាក់ព័ន្ធ ដែលអាចនឹងប្រើប្រាស់បាន ។

# ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (បន្ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ (បន្ត)

### (ទ) សម្ព័ន្ធញាតិ

ភាគីដែលត្រូវបានចាត់ទុកជាសម្ព័ន្ធញាតិរបស់ក្រុមហ៊ុន ប្រសិនបើភាគីមួយមានលទ្ធភាពគ្រប់គ្រងដោយផ្ទាល់ ឬដោយប្រយោល ឬមានឥទ្ធិពលយ៉ាងខ្លាំងទៅលើភាគីមួយទៀតក្នុងការធ្វើសេចក្តីសំរេចលើហិរញ្ញវត្ថុ និងប្រតិបត្តិការ ឬផ្ទុយមកវិញ បើក្រុមហ៊ុន និងភាគីនោះស្ថិតនៅក្រោមការគ្រប់គ្រងរួមមួយ ឬក៏មានឥទ្ធិពលយ៉ាងខ្លាំង ។ សម្ព័ន្ធញាតិអាចជារូបវន្តបុគ្គល ឬនិតិបុគ្គល ហើយរូបវន្តបុគ្គលនៃសមាជិកគ្រួសារដែលជិតស្និទ្ធក៏ត្រូវបានចាត់ទុកជាសម្ព័ន្ធញាតិផងដែរ ។

នៅក្រោមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និយមន័យរបស់សម្ព័ន្ធញាតិរួមបញ្ចូលផងដែរ នូវភាគីដែលកាន់កាប់ភាគហ៊ុន ដោយផ្ទាល់ ឬដោយប្រយោលយ៉ាងតិច 10% នៃដើមទុនរបស់ក្រុមហ៊ុន ឬនៃសិទ្ធិបោះឆ្នោត និងរាប់បញ្ចូលនូវរូបវន្តបុគ្គល ណាម្នាក់ដែលរួមចំណែកក្នុងអភិបាលកិច្ច ការដឹកនាំ ការគ្រប់គ្រង ឬការរៀបចំ និងការអនុវត្តន៍នូវការត្រួតពិនិត្យផ្ទៃក្នុង របស់ក្រុមហ៊ុន ។

### (ធ) ស្តង់ដារ និងការបកស្រាយថ្មី ដែលមិនទាន់អនុវត្តន៍

ដូចមានចែងក្នុងប្រកាសលេខ 068 សហវ-ប្រក ចុះថ្ងៃទី 8 ខែ មករា ឆ្នាំ 2009 ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តន៍ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា ក្រុមប្រឹក្សាជាតិគណនេយ្យបានអនុម័តឱ្យប្រើស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ ដែលមានប្រសិទ្ធភាពអនុវត្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ សំរាប់ការិយបរិច្ឆេទចាប់ផ្តើមនៅ ឬបន្ទាប់ពីថ្ងៃទី 1 ខែ មករា ឆ្នាំ 2012 ។ ស្តង់ដារថ្មីនេះនឹងត្រូវបានកំណត់ជា ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។ ការអនុវត្តន៍ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជានេះរំពឹងទុកថា នឹងមានផលប៉ះពាល់ជាសារវ័ន្តដល់របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ។

## 4. ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាដុល្លារអាមេរិក ។ ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល ត្រូវបានធ្វើឡើង ដើម្បីអនុវត្តទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយប្រើប្រាស់អត្រាប្តូរប្រាក់ជាផ្លូវការ ប្រកាសដោយធនាគារជាតិនៃកម្ពុជា នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009 ដែល 1 ដុល្លារអាមេរិក ស្មើនឹង 4,169 រៀល (2008: 4,081 រៀល) ។ តួលេខជាប្រាក់រៀលនេះ គឺសំរាប់ជាការបង្ហាញតែប៉ុណ្ណោះ ហើយមិនត្រូវបាន យកមកបកស្រាយថា តួលេខប្រាក់ដុល្លារអាមេរិកនេះ ត្រូវបានប្តូរទៅជាប្រាក់រៀល ឬនឹងត្រូវបានប្តូរជាប្រាក់រៀលនាពេលអនាគត តាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ ។

## 5. សាច់ប្រាក់ក្នុងដៃ

| | 2009 | | 2008 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ទីស្នាក់ការកណ្តាលនៅភ្នំពេញ | 4,808 | 20,045 | 15,189 | 61,986 |
| សាខានៅខេត្តកណ្តាល | 2,653 | 11,060 | - | - |
| | 7,461 | 31,105 | 15,189 | 61,986 |

ចំនួនខាងលើ ត្រូវបានធ្វើការវិភាគដូចខាងក្រោម៖

| | 2009 | | 2008 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់រៀល | 629 | 2,622 | 414 | 1,689 |
| ប្រាក់ដុល្លារអាមេរិក | 6,832 | 28,483 | 14,775 | 60,297 |
| | 7,461 | 31,105 | 15,189 | 61,986 |

## 6. ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា

| | 2009 | | 2008 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| *គណនីចរន្ត* | | | | |
| ធនាគារអភិវឌ្ឍន៍ជនបទ | 878 | 3,660 | 731 | 2,983 |
| ធនាគារជាតិនៃកម្ពុជា | 391 | 1,630 | 319 | 1,302 |
| ធនាគារអេស៊ីលីដា ភីអិលស៊ី | 100 | 417 | 100 | 408 |
| ធនាគារកាណាឌីយ៉ា អ.ក | 502 | 2,093 | 500 | 2,041 |
| *គណនីសន្សំ* | | | | |
| ធនាគារអេស៊ីលីដា ភីអិលស៊ី | 18,059 | 75,288 | 51,458 | 210,000 |
| ធនាគារកាណាឌីយ៉ា | 6,880 | 28,683 | 140,854 | 574,825 |
| | 26,810 | 111,771 | 193,962 | 791,559 |

# ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (បន្ត)
## សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2009

### 6. ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារនានា (បន្ត)

ចំនួនខាងលើ ត្រូវបានធ្វើការវិភាគដូចខាងក្រោម:

| | 2009 | | 2008 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| (ក) តាមកាលកំណត់: | | | | |
| ក្នុងរយៈពេល 1 ខែ | 26,810 | 111,771 | 193,962 | 791,559 |
| (ខ) តាមរូបិយប័ណ្ណ: | | | | |
| ប្រាក់ដុល្លារអាមេរិក | 26,810 | 111,771 | 193,962 | 791,559 |

(គ) តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ):

| | 2009 | 2008 |
|---|---|---|
| គណនីចរន្ត | 0.75% | សូន្យ |
| គណនីសន្សំ | 0.50% - 0.75% | 0.50% - 0.75% |

### 7. ប្រាក់បញ្ញើតម្កល់តាមច្បាប់

| | 2009 | | 2008 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់លើ: | | | | |
| ដើមទុនចុះបញ្ជី | 20,500 | 85,464 | 13,500 | 55,094 |

ប្រាក់បញ្ញើតម្កល់តាមច្បាប់ ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ដោយអនុលោមទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ7-00-006 ប្រក និង ធ7-06-209 ប្រក ស្តីពីការផ្តល់អាជ្ញាប័ណ្ណ ចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ប្រាក់បញ្ញើទាំងនេះ ត្រូវបានកំណត់ ដោយភាគរយនៃដើមទុន ដែលបានចុះបញ្ជីរបស់ក្រុមហ៊ុន ។

## 7. ប្រាក់បញ្ញើតម្កល់តាមច្បាប់ (បន្ត)

ប្រាក់បញ្ញើតម្កល់តាមច្បាប់លើដើមទុន ដែលបានចុះបញ្ជី គឺអាចដកមកវិញបាន នៅពេលដែលក្រុមហ៊ុនបញ្ចប់ប្រតិបត្តិការអាជីវកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ប្រាក់បញ្ញើតាមច្បាប់លើដើមទុនដែលបានចុះបញ្ជីរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ជាប្រាក់ដុល្លារអាមេរិក ទទួលបាន អត្រាការប្រាក់ស្មើនឹង 3/8 នៃអត្រា SIBOR ដោយគិតលើមូលដ្ឋាន 6 ខែ ។

## 8. ឥណទានផ្តល់ដល់អតិថិជន

| | 2009 | | 2008 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានជាក្រុម | 13,499 | 56,277 | 42,765 | 174,524 |
| ឥណទានជាឯកត្តជន | 1,704,307 | 7,105,256 | 1,330,309 | 5,428,991 |
| | 1,717,806 | 7,161,533 | 1,373,074 | 5,603,515 |
| សំវិធានធនសំរាប់ឥណទាន អាក្រក់ និងជាប់សង្ស័យ | | | | |
| - សំវិធានធនជាក់លាក់ | (16,199) | (67,533) | (789) | (3,220) |
| - សំវិធានធនទូទៅ | (17,550) | (73,166) | - | - |
